# ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា និង សមាគមពុទ្ធសាសនិកជនខ្មែរ

Cambodia Watchdog Council International and Khmer Buddhist Society NORWAY

ក្រុងគ្រីស្ទានសាន់ ថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៨

## លិខិតរំលែកទុក្ខ
## ជូនចំពោះក្រុមគ្រួសារសព លោក ស៊ាន ប៉េងសែ

ក្នុងនាមក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា និងសមាគមពុទ្ធសាសនិកជនខ្មែរ (សហគមន៍ខ្មែរ) នៅប្រទេសន័រវេស៍ ខ្ញុំសូមចូលរួមរំលែកមរណទុក្ខយ៉ាងក្រៀមក្រំ ជាមួយក្រុមគ្រួសារ និងសមាជិកសមាជិកានៃ គណៈកម្មាធិការព្រំដែនកម្ពុជា ប្រទេសបារាំង បន្ទាប់ពីបានទទួលដំណឹងថា **លោក ស៊ាន ប៉េងសែ** ជាស្ថានិក និងប្រធានគណៈកម្មាធិការព្រំដែនកម្ពុជា ទទួលមរណភាព នាថ្ងៃទី ២៣ ខែមករា ឆ្នាំ២០១៨ ម៉ោង ៤ ភ្លឺ ដោយរោគាពាធ នៅមន្ទីរពេទ្យ ទីក្រុងប៉ារីស ប្រទេសបារាំង (Centre Hospitalier d'Orgemont, 77100 Meaux, France) ក្នុងជន្មាយុ ៨២ ឆ្នាំ។

មរណភាពរបស់ **លោក ស៊ាន ប៉េងសែ** គឺជាការបាត់បង់អ្នកជំនាញការគូសផែនទីខ្មែរ និង ជាធនធានមនុស្សរបស់ពលរដ្ឋខ្មែរដ៏ល្អម្នាក់ ដែលបានចំណាយពេលស្ទើរតែពាក់កណ្តាលជីវិត ដើម្បីបុព្វហេតុការពារបូរណភាពទឹកដីខ្មែរ និងការផ្តួចផ្តើមគំនិតតវ៉ារឿងប្រជុំ កោះត្រល់ ពីប្រទេសវៀតណាម នៅលើមូលដ្ឋានច្បាប់ជាតិ-អន្តរជាតិ ដែលពាក់ព័ន្ធកិច្ចការរបស់កម្ពុជា បើទោះបីជារបបដឹកនាំរបស់លោក ហ៊ុន សែន មិនខ្វល់ខ្វាយអំពីការបាត់បង់ទឹកដី និងប្រជុំ កោះត្រល់ ទៅប្រទេសជិតខាងក្តី។

វីរភាព និងកិច្ចប្រឹងប្រែងរបស់លោក ព្រមទាំងសមាជិកនៃ គណៈកម្មាធិការព្រំដែនកម្ពុជា បានផ្តល់ឯកសារស្រាវជ្រាវផ្លូវច្បាប់ផង និងលើកទឹកចិត្តដល់យុវជនខ្មែរ ពលរដ្ឋខ្មែរ ឲ្យចេះចូលរួមការពារបូរណភាពទឹកដីខ្មែរ និងឲ្យចេះស្រឡាញ់ប្រទេសជាតិ។

ជាទីបញ្ចប់ យើងខ្ញុំសូមឧទ្ទិសកុសលផលបុណ្យ ជូនវិញ្ញាណខន្ធ **លោក ស៊ាន ប៉េងសែ** ឲ្យបានដល់ឋានសុគតិភព កុំបីឃ្លៀងឃ្លាតឡើយ។

**ប្រធាន**

**ម៉ែន ណាត**

អសយដ្ឋាន ទីក្រុងគ្រីស្ទានសាន់ ប្រទេសន័រវេស៍ /ប្រអប់សំបុត្រ #Senterveien 40, Apartment 112, 4790 Lillesand, NORWAY
Phone: (+47)90818257, E-mail: post: post@cwcicambodia.com /nathamonin@gmail.com /Web: www.cwcicambodia.com